**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខៈ ៦៦.សសរ**

# សេចក្តីសម្រេច

## ស្តីពី

## ការរៀបចំនិងការប្រព្រឹត្តទៅនៃក្រុមការងារជាន់ខ្ពស់ដើម្បីជំរុញគម្រោងវិនិយោគអាទិភាពរួមរវាងព្រះរាជាណាចក្រកម្ពុជា និងសហព័ន្ធរុស្ស៊ី

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៦ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងពាណិជ្ជកម្ម
- បានឃើញអនុក្រឹត្យលេខ ១៣១ អនក្រ.បក ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០១៤ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងពាណិជ្ជកម្ម
- យោងតាមការចាំបាច់របស់រាជរដ្ឋាភិបាល

## សម្រេច

## ជំពូកទី១

## បទប្បញ្ញត្តិទូទៅ

**ប្រការ១ ..**

ត្រូវបានបង្កើតក្រុមការងារជាន់ខ្ពស់ ដើម្បីជំរុញគម្រោងវិនិយោគអាទិភាពរួម រវាងព្រះរាជាណាចក្រកម្ពុជានិងសហព័ន្ធរុស្ស៊ី ក្នុងគោលបំណងសម្របសម្រួល និងធានាប្រសិទ្ធភាពនៃការអនុវត្តបណ្តាគម្រោងអាទិភាពរួមដែលជាប្រយោជន៍នៃប្រទេសទាំងពីរ។

## ជំពូកទី២
## សមាសភាព

**ប្រការ២ ..**

ក្រុមការងារជាន់ខ្ពស់ដើម្បីជំរុញគម្រោងវិនិយោគអាទិភាពរួមរវាងព្រះរាជាណាចក្រកម្ពុជា និងសហព័ន្ធរុស្ស៊ី មានសមាសភាពដូចខាងក្រោម៖

| | | |
|---|---|---|
| ១- ឯកឧត្ដម **ស៊ុន ចាន់ថុល** | ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម | ប្រធាន |
| ២- ឯកឧត្ដម **អ៊ុច បូររិទ្ធ** | រដ្ឋលេខាធិការក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ | អនុប្រធាន |
| ៣- ឯកឧត្ដម **ជា វុទ្ធី** | អគ្គលេខាធិការរងគណៈកម្មាធិការវិនិយោគកម្ពុជា នៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា | អនុប្រធាន |
| ៤- ឯកឧត្ដម **ហ៊ីង ថូរ៉ាក់ស៊ី** | រដ្ឋលេខាធិការទីស្ដីការគណៈរដ្ឋមន្ត្រី | សមាជិក |
| ៥- ឯកឧត្ដម **សាត សាមី** | រដ្ឋលេខាធិការក្រសួងឧស្សាហកម្ម និងសិប្បកម្ម | សមាជិក |
| ៦- ឯកឧត្ដម **វង្សី វិស្សុត** | រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | សមាជិក |
| ៧- ឯកឧត្ដម **ម៉ម អំណាត់** | រដ្ឋលេខាធិការក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | សមាជិក |
| ៨- ឯកឧត្ដម **សុខ ខាន់ទ៉ាន់** | រដ្ឋលេខាធិការក្រសួងរ៉ែ និងថាមពល | សមាជិក |
| ៩- ឯកឧត្ដម **ភាន ច័ន្ទមេត្តា** | រដ្ឋលេខាធិការក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ | សមាជិក |
| ១០- ឯកឧត្ដម **លឹម ស៊ីដេនីន** | រដ្ឋលេខាធិការក្រសួងសាធារណការនិងដឹកជញ្ជូន | សមាជិក |
| ១១- ឯកឧត្ដម **និត ចន្ថា** | រដ្ឋលេខាធិការក្រសួងទេសចរណ៍ | សមាជិក |
| ១២- ឯកឧត្ដម **ម៉ែន សុផល** | រដ្ឋលេខាធិការក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ | សមាជិក |
| ១៣- ឯកឧត្ដម **សួន សុខឃឹម** | អនុរដ្ឋលេខាធិការក្រសួងផែនការ | សមាជិក |
| ១៤- លោកជំទាវ **អ៊ុក ម៉ាលី** | អគ្គទេសាភិបាលរងនៃធនាគារជាតិនៃកម្ពុជា | សមាជិកា |
| ១៥- លោកជំទាវ **ម៉ែន មុន្នីមករា** | អនុរដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល | សមាជិកា |
| ១៦- លោក **ជា សុជាតិ** | ប្រធាននាយកដ្ឋានអឺរ៉ុប មជ្ឈិមបូព៌ា និងអាហ្វ្រិក នៃក្រសួងពាណិជ្ជកម្ម | លេខាធិការ។ |

សមាសភាពក្រុមការងារជាន់ខ្ពស់នេះ អាចត្រូវបានស្នើសុំបន្ថែមដោយប្រធានក្រុមការងារតាមការចាំបាច់។

## ជំពូកទី៣
## តួនាទី និងភារកិច្ច

**ប្រការ៣ ..**

ក្រុមការងារជាន់ខ្ពស់ដើម្បីជំរុញគម្រោងវិនិយោគអាទិភាពរួមរវាងព្រះរាជាណាចក្រកម្ពុជា និងសហព័ន្ធរុស្ស៊ី មានតួនាទីនិងភារកិច្ចដូចខាងក្រោម៖

- រៀបចំគោលនយោបាយ ផែនការសកម្មភាព និងយុទ្ធសាស្ត្រសម្រាប់ជំរុញនិងគាំទ្រដល់ការពង្រីកកិច្ចសហប្រតិបត្តិការ និងលើកកម្ពស់វិស័យវិនិយោគអាទិភាពរួមទ្វេភាគី និងត្រូវធានាឱ្យគោលនយោបាយ និងកម្មវិធីទាំងឡាយ ស្របគ្នាជាមួយនឹងផែនការអភិវឌ្ឍន៍ជាតិរបស់រាជរដ្ឋាភិបាល
- ចូលរួមចរចា និងប្រជុំពិភាក្សាការងារជាមួយសមភាគីលើការងារទាក់ទងនឹងគម្រោងវិនិយោគអាទិភាពរួម

- រៀបចំបញ្ជីគម្រោងវិនិយោគអាទិភាពរួម សម្រាប់កិច្ចសហប្រតិបត្តិការរវាងព្រះរាជាណាចក្រកម្ពុជា និងសហព័ន្ធរុស្ស៊ី
- លើកជាសំណើនិងអនុសាសន៍ផ្សេងៗ ដើម្បីបំពេញបន្ថែមនិងកែសម្រួលបញ្ជីគម្រោងវិនិយោគអាទិភាពរួម
- ធ្វើជាសេនាធិការដោះស្រាយបញ្ហាផ្សេងៗ ដែលកើតឡើងក្នុងអំឡុងពេលដែលអនុវត្តគម្រោងតាមរយៈការពិគ្រោះយោបល់ និងការចរចា
- តាមដាន វាយតម្លៃលើការអនុវត្តគម្រោង និងធ្វើរបាយការណ៍អំពីវឌ្ឍនភាពសកម្មភាពអនុវត្តការងារ និងលទ្ធផលការងារ ព្រមទាំងផ្តល់អនុសាសន៍តាមការចាំបាច់ជូនរាជរដ្ឋាភិបាល
- ធ្វើរបាយការណ៍ស្តីពីលទ្ធផលការងារជូនប្រមុខរាជរដ្ឋាភិបាល តាមរយៈទីស្តីការគណៈរដ្ឋមន្ត្រី
- បំពេញការងារដទៃទៀត តាមការណែនាំរបស់ប្រមុខរាជរដ្ឋាភិបាល។

**ប្រការ៤ ..**

សមាជិកក្រុមការងារជាន់ខ្ពស់នេះ ត្រូវចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធាន។ ក្នុងករណីប្រធានអវត្តមាន ប្រធានអាចផ្ទេរសិទ្ធិជូនអនុប្រធានឬតំណាង ដើម្បីដឹកនាំប្រជុំជំនួស។

## ជំពូកទី៤
## ការប្រព្រឹត្តទៅ

**ប្រការ៥ ..**

ក្រុមការងារជាន់ខ្ពស់នេះ អាចអញ្ជើញតំណាងក្រសួង-ស្ថាប័ន វិស័យឯកជន អ្នកជំនាញការជាតិ និងអន្តរជាតិ ឬភាគីពាក់ព័ន្ធផ្សេងទៀតដើម្បីពិគ្រោះយោបល់ ឬចូលរួមក្នុងកិច្ចប្រជុំរបស់ខ្លួន ឬចូលរួមក្នុងការងារសិក្សាស្រាវជ្រាវ ផ្តល់យោបល់ដើម្បីកែលម្អ និងធ្វើឱ្យកិច្ចសហប្រតិបត្តិការកាន់តែមានប្រសិទ្ធភាព។

**ប្រការ៦ ..**

ប្រធានក្រុមការងារជាន់ខ្ពស់ អាចបង្កើតក្រុមការងារតូចៗ និងក្រុមពិគ្រោះយោបល់តាមការចាំបាច់ ដើម្បីជួយបំពេញការងាររបស់ខ្លួនឱ្យមានប្រសិទ្ធភាពខ្ពស់។

សមាសភាព និងតួនាទីភារកិច្ចរបស់ក្រុមការងារតូចៗ និងក្រុមពិគ្រោះយោបល់ ត្រូវកំណត់ដោយសេចក្តីសម្រេចរបស់ប្រធានក្រុមការងារជាន់ខ្ពស់។

**ប្រការ៧ ..**

ក្រុមការងារជាន់ខ្ពស់មានលេខាធិការដ្ឋានមួយ ជាសេនាធិការ ស្ថិតនៅនាយកដ្ឋានអឺរ៉ុប មជ្ឈិមបូព៌ា និង អាហ្វ្រិកនៃក្រសួងពាណិជ្ជកម្ម។

លេខាធិការដ្ឋានរបស់ក្រុមការងារជាន់ខ្ពស់ ត្រូវដឹកនាំដោយប្រធានលេខាធិការដ្ឋាន ០១ (មួយ) រូប និងមាន អនុប្រធានមួយចំនួនជាជំនួយការតាមការចាំបាច់។

ការរៀបចំ និងការប្រព្រឹត្តទៅនៃលេខាធិការដ្ឋានក្រុមការងារជាន់ខ្ពស់ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្មដែលជាប្រធានក្រុមការងារជាន់ខ្ពស់។

**ប្រការ៨ ..**

ក្រុមការងារជាន់ខ្ពស់មានសិទ្ធិប្រើប្រាស់ត្រារបស់ក្រសួងពាណិជ្ជកម្ម ដើម្បីបំពេញការងាររបស់ខ្លួន។

**ប្រការ៩.-**

ក្រុមការងារជាន់ខ្ពស់នេះ មានសិទ្ធិប្រើប្រាស់ថវិការបស់ក្រសួងពាណិជ្ជកម្ម ឬមូលនិធិដែលបានពីដៃគូអភិវឌ្ឍន៍ ដើម្បីដំណើរការការងាររបស់ខ្លួន។

**ជំពូកទី៥**

**អវសានប្បញ្ញត្តិ**

**ប្រការ១០.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងសេចក្តីសម្រេចនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ១១.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម រដ្ឋមន្ត្រីក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែសីហា ឆ្នាំ២០១៥

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជម្រាបជូន

សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី សូមហត្ថលេខា

**ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម**

**ស៊ុន ចាន់ថុល**

**កន្លែងទទួល:**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចប្រការ១១
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ